# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពាក្យខ្មែរមួយឃ្លាថា ចាញ់បានជាព្រះឈ្នះបានជាមារ ។

**web site: hoksavann.org**

ថ្ងៃទី៩ កក្កដា ២០០៥

ពាក្យថា ចាញ់បានជាព្រះ ឈ្នះបានជាមារនេះ ជាពាក្យចេញមកពីមជ្ឈដ្ឋានអ្នកកាន់ពុទ្ធសាសនាខ្មែរ ។ ពាក្យចាញ់និងឈ្នះតាមផ្លូវលោកនិងផ្លូវធម៌ មានន័យខុសគ្នា ។ ជំនះផ្លូវលោក គឺគេឲ្យតម្លៃទៅលើអ្នកដែលមានប្រៀបទៅលើគូប្រជែងម្ខាងទៀត ដូចជាឈ្នះដោយលេងល្បែងផ្សេងៗ ឈ្នះដោយច្បាំងគ្នា ដោយម្ខាងមានប្រៀបទៅលើគូប្រជែងម្ខាងទៀតជាដើម ។ ឯពាក្យថាចាញ់ គឺចាញ់គូប្រជែងម្ខាងទៀតនោះឯង ។ តាមន័យផ្លូវធម៌ ឈ្នះរបៀបនេះ ពុំមែនជាជំនះពិតប្រាកដ ជាជំនះតាំងនៅជាស្ថាពរឡើយ ជាជំនះនឹងត្រឡប់ចាញ់វិញ ហើយប្រកបដោយការចងពៀរនឹងគ្នាទៀតផង ។ ចំណែកជំនះផ្លូវធម៌វិញ គឺឈ្នះផ្លូវចិត្តខ្លួនឯង ដោយមិនធ្វើអំពើបាបគ្រប់យ៉ាង ដោយមានចិត្តបរិសុទ្ធ ឈ្នះសត្រូវ គឺកិលេសគ្រឿងសៅហ្មងចិត្ត ។ បានសេចក្តីតាមផ្លូវធម៌ថា ឈ្នះសេចក្តីអាក្រក់ខ្លួនឯង ដោយការពុំបៀតបៀនអ្នកដទៃ ឈ្មោះថាជាអ្នកឈ្នះពិតប្រាកដ ។ អ្នកឈ្នះអ្នកដទៃដោយអំពើហឹង្សា អ្នកនោះតែងមានសេចក្តីក្តៅក្រហាយខ្លួនឯង បង្កើតអសន្តិសុខនៅក្នុងចិត្តរបស់ខ្លួនជានិច្ច បានន័យថា ជាអ្នកចាញ់ខ្លួនឯង ។ អំពើអាក្រក់ដែលកើតអំពីការចងគំនុំផ្ចាល់ខ្លួនក្តី តាមផ្លូវនយោបាយក្តី ឈ្មោះថាជាអ្នកចាញ់ ព្រោះអំពើអាក្រក់នោះនឹងវិលត្រឡប់ឲ្យទុក្ខដល់ខ្លួនវិញ ។ អ្នកដែលរំលោភឈ្លានពានគេ ឈ្មោះថាជាអ្នកចាញ់ គឺចាញ់ដោយសារតែបណ្តោយឲ្យអំពើអាក្រក់ ដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឈ្នះ ។ ចំណែកបុគ្គលដែលមិនបៀតបៀនអ្នកដទៃ មិនរំលោភសិទ្ធិអ្នកដទៃ ឈ្មោះថាជាអ្នកឈ្នះ គឺឈ្នះសេចក្តីអាក្រក់មិនឲ្យកើតមានក្នុងចិត្តរបស់ខ្លួន អ្នកនោះនឹងត្រូវបានរង្វាន់តបវិញ គឺការស្រឡាញ់រាប់អានពីជនទូទៅ ដែលជាហេតុនាំឲ្យបានសេចក្តីសុខ ។ ពាក្យថា ចាញ់បានជាព្រះ បើនិយាយពីព្រះពុទ្ធអ្នកត្រាស់ដឹង គឺចាញ់ត្រង់ព្រះអង្គពុំធ្វើអំពើអាក្រក់ដូចបុគ្គលពាល តែចាញ់ដើម្បីឈ្នះ គឺឈ្នះ

កិលេសតណ្ហា ឈ្នះអំពើអាក្រក់គ្រប់យ៉ាង គឺទីបំផុតព្រះអង្គមានជ័យជំនះ បានត្រាស់ជាព្រះពុទ្ធ ។ ពាក្យថា ព្រះពុទ្ធឈ្នះមារ គឺឈ្នះសេចក្តីអាក្រក់គ្រប់យ៉ាងមានកិលេសមារជាដើម ។ បើព្រះនៅក្នុងទីនេះឲ្យន័យថាប្រសើរវិញ គឺអ្នកដែលមិនធ្វើអំពើបាបនេះហើយ ជាអ្នកប្រសើរ ។ ពាក្យថាចាញ់នេះពុំមែនមានន័យថា មិនតស៊ូដោះស្រាយបញ្ហាជីវិតឡើយ ផ្ទុយទៅវិញ ពាក្យថាចាញ់នេះ គឺចាញ់មិនធ្វើបាបដើម្បីជ័យជំនះតាមលក្ខណៈរបស់លោកអ្នកសប្បុរសតាមមាគ៌ាគតិបណ្ឌិតឈ្មោះថាជាអ្នកតស៊ូអត់សង្កត់ចិត្តមិនសាងអាក្រក់ ឈ្មោះថាជាអ្នកឈ្នះ ។ ឯអ្នកដែលសាងអាក្រក់ ទីបំផុតនឹងត្រូវទទួលបរាជ័យដោយអំពើអាក្រក់របស់ខ្លួន ឈ្មោះថាជាអ្នកចាញ់ ។៚

⌘ ⌘

⌘